ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីវិនិយោគសាធារណៈ

# ៣ឆ្នាំរំកិល

# ២០១៩ - ២០២១

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

**រៀបចំដោយក្រសួងផែនការ**

# បុព្វកថា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍បញ្ជាក់ឱ្យដឹងថា ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨*** គឺជាឯកសារសំខាន់មួយសម្រាប់គ្រប់គ្រងការវិនិយោគនិងការអភិវឌ្ឍលើវិស័យសាធារណៈនៅកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៦ ក្រសួងផែនការជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ***កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល*** ជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់តម្រូវការជំនួយវិនិយោគជាទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្ត**ផ.យ.អ.ជ.**។ ក្នុងការរៀបចំ**ក.វ.ស. ៣ឆ្នាំរំកិល** ចាប់ផ្តើមពីឆ្នាំ២០០៦-២០០៨ មកដល់ឆ្នាំ២០១៩-២០២១នេះ ការវិភាជថវិកាបាននិងកំពុង ឆ្លើយតបទៅនឹងការវិភាជដែលមានចែងនៅក្នុង***ផ.យ.អ.ជ. ២០០៦-២០១០ ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣*** និង***ផ.យ.អ.ជ. ២០១៤-២០១៨***។

ក្រសួងផែនការបានបន្តធ្វើការកែសម្រួលបន្ថែមទៀតលើដំណើរការរៀបចំ***ក.វ.ស. ៣ឆ្នាំរំកិល ២០១៩-២០២១*** ដោយបានរៀបចំការពិភាក្សាដោយផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ននីមួយៗ ដើម្បីធានាថាការផ្ញើទិន្នន័យគម្រោងរបស់បណ្តាក្រសួង ស្ថាប័នទាំងអស់សម្រាប់ រៀបចំ***ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១*** បានឆ្លើយតបទៅនឹងអាទិភាពរបស់***ផ.យ.អ.ជ. ២០១៤-២០១៨***។

***ផ.យ.អ.ជ. ២០១៤-២០១៨*** បានចែងយ៉ាងច្បាស់លាស់ពីទំនាក់ទំនងនៃ***ផ.យ.អ.ជ. ក.វ.ស. ៣ឆ្នាំរំកិល*** *ក្របខ័ណ្ឌ****ចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ***។ បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងបន្តសម្របសម្រួលនិងប្រឹងប្រែងទាំងអស់គ្នាដើម្បីធានាបាននូវសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ។

ខ្ញុំមានសេចក្តីរីករាយ និងសូមធ្វើការបង្ហាញនូវ***ក.វ.ស.៣ឆ្នាំរំកិល២០១៩-២០២១***សម្រាប់ជាព័ត៌មាននិងការប្រើប្រាស់របស់រាជរដ្ឋាភិបាលកម្ពុជា និងទាំងដៃគូអភិវឌ្ឍទាំងអស់។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់ឡើងវិញម្តងទៀត និងជំរុញដល់ដៃគូអភិវឌ្ឍដែលផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់ប្រទេសកម្ពុជាត្រូវមានមូលដ្ឋានពិនិត្យលើគម្រោង**សម្រាប់អនុវត្តផ.យ.អ.ជ.** នៃបញ្ជីគម្រោង***ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១*** ដែលនឹងនាំយើងឈានទៅសម្រេចបាននូវគោលបំណងនិងអាទិភាពដែលមានចែងនៅក្នុង***ផ.យ.អ.ជ. ២០១៤-២០១៨*** និងដើម្បីកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**ក្រសួងផែនការ**
ខែ សីហា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# មាតិកា

**ទំព័រ**


បុព្វកថា ........................................................................................................ i

សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ................................................ ii

មាតិកា ........................................................................................................ iii

ជំពូកទី១- សេចក្តីផ្តើម

ដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ ........................................................................... ១

វិធីសាស្ត្រសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៩-២០២១ ..................... ២

ជំពូកទី២-ទស្សនវិស័យសេដ្ឋកិច្ចឆ្នាំ២០១៩-២០២១ ................................................ ៦

ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប ២០១៩-២០២១ ..................................៦

អត្រាកំណើនផ.ស.ស.ពិត(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ...................................................៧

ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចនូវកំណើនផ.ស.ស.ដែលបានគ្រោងទុក ................... ៨

ចំណូលនិងចំណាយថវិកា២០១៩-២០២១...................................................... ១២

ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៩-២០២១ ........................................................................................................ ១៣

ជំពូកទី៣- កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៩-២០២១ ............................ ១៧

ជំពូកទី៤- សេចក្តីសន្និដ្ឋាន ................................................................................ ៤៦


## បញ្ជីតារាង


តារាងទី១- ការព្យាករពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ................................................ ៧

តារាងទី២- អត្រាកំណើនផ.ស.ស.(ថ្លៃថេរឆ្នាំ២០០០)តាមវិស័យ............................................ ៨

តារាងទី៣- ការវិនិយោគមូលធនចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុកនិងធនធាន

ដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់ ...................................... ១០
តារាងទី៤- វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅនៃកំណើន ផ.ស.ស. ...................................................................................................... ១១
តារាងទី៥- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៧- ២០១៩ ................................................................................................................ ១៤
តារាងទី៦- ការវិភាជតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការវិភាជតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨ ....... ១៥
តារាងទី៧- ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨ និងក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ ........................ ១៧
តារាងទី៨- សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ .......................................... ២០
តារាងទី៩- គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកតាមវិស័យអាទិភាពនៃផ.យ.អ.ជ. ២០១៤-២០១៨ ដែលក្រសួង ស្ថាប័នស្នើសុំ ...................................... ២១
តារាងទី១០- បរិមាណខុសគ្នានៃការវិភាជតាមអនុវិស័យផ.យ.អ.ជ.២០១៤-២០១៨ និងការស្នើសុំដោយក្រសួង ស្ថាប័ន ........................................................................................... ៤១
តារាងទី១១- សេចក្តីសង្ខេបការវិភាជតាមវិស័យក្នុងផ.យ.អ.ជ.២០១៤-២០១៨ និងចំណាយប៉ាន់ស្មានតាមក្រសួង ស្ថាប័ន ..........................................................................................៤២
តារាងទី១២- បញ្ជីគម្រោងបែងចែកតាមក្រសួង ស្ថាប័ន ...................................................... ៤៧
តារាងទី១៣- បញ្ជីគម្រោងតាមវិស័យផ.យ.អ.ជ. ២០១៤-២០១៨.......................................... ១៤០

# ជំពូកទី១

## សេចក្តីផ្តើម

១- គោលបំណងសំខាន់នៃ*កម្មវិធីវិនិយោគសាធារណៈ(ក.វ.ស.) ៣ឆ្នាំរំកិល២០១៩-២០២១* គឺធ្វើការបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាគោលនយោបាយមានចែងនៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* និងជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨*។ *ផ.យ.អ.ជ. ២០១៤-២០១៨* ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានរៀបចំឡើងដោយមានមូលដ្ឋានពីធាតុចូលរបស់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

២- *ក.វ.ស. ៣ឆ្នាំរំកិល* បានដាក់បញ្ចូលគ្នា*គម្រោងកំពុងដំណើរការ* ដែលការអនុវត្តគម្រោងកំពុងបន្តនៅក្នុងដំណាក់កាល ក.វ.ស. និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ជាគម្រោងស្នើសុំថ្មីដែលត្រូវអនុវត្តក្នុងដំណាក់កាល ក.វ.ស.។

ប្រភពទិន្នន័យសម្រាប់រៀបចំក.វ.ស. រួមមាន÷

(១) ព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ* ក្នុងនោះគម្រោងកំពុងដំណើរការក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងពិនិត្យកែសម្រួលដោយក្រសួង ស្ថាប័នអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា។ និង

(២) ព័ត៌មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ដែលក្រសួងផែនការបានទទួលពី ក្រសួង ស្ថាប័នទាំងអស់សម្រាប់រៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១*។

### ក- ដំណើរការនៃការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការ

៣- នៅពាក់កណ្តាលឆ្នាំ២០០៩ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើត*ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ* ដើម្បីពង្រឹងការងារសុខដុមនីយកម្ម ការងារផែនការ និងការអនុវត្តជាក់ស្តែង ដែលជាគោលដៅសំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៤- បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើការពង្រឹងសមត្ថភាពស្ថាប័នដើម្បីភ្ជាប់ទំនាក់ទំនងនៃដំណើរការ÷

(១) កំណត់តម្រូវការជាអាទិភាពសម្រាប់វិនិយោគតាមរយៈកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ដែលរៀបចំឡើងដោយក្រសួងផែនការ។

(២) រៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(៣) រៀបចំទិន្នន័យនៃគម្រោងវិនិយោគមូលធនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ និង

(៤) រៀបចំទិន្នន័យនៃគម្រោងកំពុងដំណើរការនិងការវិភាជធនធានរបស់ដៃគូអភិវឌ្ឍនានាដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥- ក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រតិបត្តិការនេះដឹកនាំដោយក្រសួងផែនការ និងមានសមាជិកមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមការងារបានរៀបចំកិច្ចប្រជុំជាច្រើនដងដើម្បីពិភាក្សានិងកំណត់ទិសដៅការងាររបស់ខ្លួន។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌការងាររួមមួយសម្រាប់ការតាមដានត្រួតពិនិត្យការងាររបស់ក្រុមការងារ ត្រូវបានកំណត់ជាសូចនាករសម្រាប់ការតាមដានរួមគ្នា(JMIs) សម្រាប់សកម្មភាពនេះ។ តាមរយៈសូចនាករសម្រាប់ការតាមដានរួមគ្នា ពេលនេះក្រុមការងារបានធ្វើការវិភាគស្ថានភាពលើការងាររបស់ខ្លួនដើម្បីឈានទៅសម្រេចបានក្របខ័ណ្ឌលទ្ធផលដែលមានចែងនៅក្នុងជំពូកទី៦នៃផ.យ.អ.ជ. ២០១៤-២០១៨។

## ២- វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៩-២០២១

៦- សម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៩-២០២១ ក្រសួងផែនការ បានបន្តធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការ នីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឈានទៅសម្រេចបាននូវ*សុខដុមនីយកម្ម ការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ និងដើម្បីពង្រឹងយន្តការស្ថាប័ននៃការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព*។

៧- វិធីសាស្ត្រសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៩-២០២១ ត្រូវបានអនុវត្តដូចការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៦-២០១៨។ ដោយវិធីសាស្ត្រថ្មីនេះ រួមមាន *គម្រោងកំពុងដំណើរការ* គឺជាគម្រោងដែលកំពុងត្រូវបានអនុវត្តឬមានកិច្ចសហការនិងការសម្របសម្រួលជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយការអនុវត្តគម្រោងទាំងនោះនឹងត្រូវបន្តនៅក្នុងកំលុងពេលនៃ ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ និង*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ឬគម្រោងថ្មី* ដែលនឹងត្រូវ

អនុវត្តក្នុងកំលុងពេលនៃក.វ.ស. ៣ឆ្នាំរំកិល ២០១៩-២០២១។ គម្រោងកំពុងដំណើរការ គឺត្រូវបានដាក់បញ្ចូលនូវគម្រោងដែលកំពុងអនុវត្តដោយអង្គការសង្គមស៊ីវិលនានា ដោយសហការជាមួយក្រសួង ស្ថាប័នតាមវិស័យពាក់ព័ន្ធ។ ព័ត៌មានសម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ ត្រូវបានធ្វើការកែលម្អតាមរយៈកម្រងបញ្ជីសំណួរថ្មីដែលបានចែកចេញជាពីរផ្នែក។ ផ្នែកទី១ គឺការប្រមូលព័ត៌មានស្តីពី*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* និងផ្នែកទី២ គឺការប្រមូលព័ត៌មានស្តីពី*គម្រោងកំពុងដំណើរការ*ដែលបញ្ជីសំណួរ ក.វ.ស. ៣ឆ្នាំរំកិលថ្មី។

៨- សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ ក្រសួងផែនការបានស្នើដល់ក្រសួង ស្ថាប័នឱ្យពិនិត្យមើលព័ត៌មានស្តីពីការចំណាយជំនួយអភិវឌ្ឍផ្លូវការដែលដៃគូអភិវឌ្ឍរាយការណ៍នៅក្នុងប្រព័ន្ធទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាជារៀងរាល់ឆ្នាំ ដែលរួមមានគម្រោងកំពុងដំណើរនិងគម្រោងអាទិភាពខ្ពស់របស់ដៃគូអភិវឌ្ឍ។ គម្រោងកំពុងដំណើរការទាំងអស់ដែលរាយការណ៍ដោយដៃគូអភិវឌ្ឍគឺជាបណ្តាគម្រោងដែលកំពុងអនុវត្តដោយ÷ (១) ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល (២) ដៃគូអភិវឌ្ឍ និង(៣) សង្គមស៊ីវិល ដោយមានការគាំទ្រផ្តល់ថវិកាពីដៃគូអភិវឌ្ឍ។

៩- ប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ គឺក្រសួងផែនការបានទទួលពីគ្រប់ក្រសួង ស្ថាប័ន។ តាមរយៈការអនុវត្តជាក់ស្តែង យើងទទួលស្គាល់ថាទិន្នន័យស្តីពីគម្រោងកំពុងដំណើរការដែលក្រសួង ស្ថាប័នផ្ញើមកក្រសួងផែនការ មានដាក់បញ្ចូលនូវគម្រោងកំពុងដំណើរការមួយចំនួន ដែលដៃគូអភិវឌ្ឍបានរាយការណ៍ជូនគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា។ ប៉ុន្តែដើម្បីធានាបាននូវការកត់ត្រាច្បាស់លាស់នូវចំនួនគម្រោងកំពុងដំណើរការដែលកំពុងអនុវត្តដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ននីមួយៗ និងដើម្បីជួយសម្រួលដល់ការរៀបចំទិន្នន័យគម្រោងកំពុងដំណើរការរបស់ក្រសួង ស្ថាប័ន ក្រសួងផែនការបានស្នើដល់ក្រសួង ស្ថាប័នឱ្យពិនិត្យបញ្ជីគម្រោងជាពិសេសគម្រោងកំពុងដំណើរការដែលមាននៅក្នុងប្រព័ន្ធទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា សម្រាប់ដាក់បញ្ចូលក្នុងក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១។

១០- ចំពោះ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលនឹងត្រូវអនុវត្តក្នុងកំលុងឆ្នាំ ២០១៩-២០២១ ក្រសួងផែនការបានផ្តល់សេចក្តីណែនាំនិងពន្យល់ដោយផ្ទាល់ដល់គ្រប់ក្រសួង ស្ថាប័នបន្ថែមពីលើការពន្យល់តាមរយៈសិក្ខាសាលាជាតិនាពេលកន្លងមក ដើម្បីធានាថាក្នុងការស្នើសុំ*គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.* ក្រសួង ស្ថាប័នទាំងអស់បាន÷

(១) វិភាគច្បាស់លាស់ពីសារៈសំខាន់នៃគម្រោងទាំងនោះ ក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយជាអាទិភាពនៃ

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ព្រមទាំងផែនការរបស់ក្រសួង ស្ថាប័នដែលមានចែងនៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨*។

(២) ពិនិត្យច្បាស់លាស់ការវិភាជតាមវិស័យអាទិភាព ដែលមានចែងនៅក្នុង *ផ.យ.អ.ជ.២០១៤-២០១៨*។

(៣) ពិនិត្យលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីរបស់ក្រសួង ស្ថាប័ននីមួយៗជាមួយអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំ *ផែនការយុទ្ធសាស្ត្រថវិកា* រយៈពេលវែងសម្រាប់ក្រសួង ស្ថាប័នរបស់ខ្លួន។

(៤) ពិនិត្យច្បាស់លាស់ពីប្រភពធនធានជាសក្តានុពលក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់ អនុវត្តផ.យ.អ.ជ.។

(៥) កំណត់ *លំដាប់អាទិភាព* ចំពោះគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.នីមួយៗ ដែលក្រសួង ស្ថាប័ន បានផ្ញើមកក្រសួងផែនការ។ នាពេលសិក្ខាសាលាជាតិស្តីពីការផ្សព្វផ្សាយដំណើរការនៃការរៀបចំ *ក.វ.ស. ៣ឆ្នាំរំកិល២០១១-២០១៣ និងក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* ក្រសួងផែនការបាន បញ្ជាក់ច្បាស់ថា÷

- អាទិភាពគម្រោងមិនអាចមានលំដាប់ដូចគ្នានៅក្នុងក្រសួង ស្ថាប័នតែមួយ
- ចំពោះករណីគម្រោងអភិក្រមគ្រប់គ្រងទូទាំងវិស័យឬកម្មវិធីធំ ត្រូវផ្តល់ព័ត៌មានស្តីពីផ្នែក ទាំងឡាយនៃគម្រោងដែលអាចទទួលបានហិរញ្ញប្បទានជាគម្រោង ព្រមទាំងគម្រោងតាមផ្នែក ផ្សេងៗទៀតដែលត្រូវការនូវការកំណត់លំដាប់អាទិភាពដោយផ្អែកលើរយៈពេលនៃការអនុវត្ត សកម្មភាពអភិក្រមគ្រប់គ្រងទូទាំងវិស័យឬសកម្មភាពដែលបានកំណត់របស់កម្មវិធីធំៗ
- ក្រសួងផែនការនឹងធ្វើការផ្តល់លេខគម្រោងដល់គ្រប់គម្រោងក.វ.ស. ៣ឆ្នាំរំកិល ទាំងអស់ ដែលថ្នាក់ដឹកនាំក្រសួង ស្ថាប័នបានកំណត់អាទិភាពនិងផ្ញើមកក្រសួងផែនការ។

១១- ក្រសួងផែនការធ្វើការវិភាជថវិកាសម្រាប់ *ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* ដោយមានមូលដ្ឋាន នៃលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម÷

- ការវិភាជសរុបសម្រាប់វិស័យដល់គម្រោងកំពុងដំណើរការ និងគម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ. ត្រូវមានសង្គតិភាពជាមួយការវិភាជតាមវិស័យដែលមានចែងនៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨។
- អាទិភាពនៃការវិភាជថវិកាដែលមានដល់បណ្តាគម្រោងកំពុងដំណើរការ ដើម្បីបន្តការអនុវត្ត និងបញ្ចប់ការអនុវត្ត។
- ថវិកាដែលនៅសល់នឹងត្រូវធ្វើការវិភាជដល់គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដោយផ្អែកលើ÷
    - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួង ស្ថាប័ន

- គម្រោងសម្រាប់អនុវត្តផ. យ. អ. ជ. ទាំងនោះសម្រាប់អនុវត្តយុទ្ធសាស្រ្តតាមវិស័យរបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ និងអាទិភាពដែលមានចែងនៅក្នុង*ផ. យ. អ. ជ. ២០១៤-២០១៨*
- ព័ត៌មានដែលក្រសួង ស្ថាប័ន បានផ្ញើមកក្រសួងផែនការស្តីពីស្ថានភាពសក្តានុពលក្នុងការសន្យាផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត*ផ. យ. អ. ជ.*
- កិច្ចពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្តល់ថវិកាពីកញ្ចប់ថវិកាជាតិ និងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួង ស្ថាប័ន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំ*ផែនការយុទ្ធសាស្រ្តថវិកា* សម្រាប់ក្រសួងស្ថាប័ននីមួយៗ។

១២- ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ*ក. វ. ស. ៣ឆ្នាំរំកិល* ក្រសួងផែនការបានរៀបចំកែសម្រួលឡើងវិញនូវប្រព័ន្ធទិន្នន័យរបស់*ក. វ. ស. ៣ឆ្នាំរំកិល* និងបញ្ចីសំណួរដាក់ក្នុងប្រព័ន្ធទិន្នន័យតាមអនឡាញ សម្រាប់ឲ្យមន្រ្តីរបស់ក្រសួង ស្ថាប័នទាំងអស់បំពេញព័ត៌មានគម្រោងរបស់ខ្លួននិងផ្ញើត្រឡប់មកក្រសួងផែនការវិញតាមប្រព័ន្ធទិន្នន័យតាមអនឡាញនេះ(pip.mop.gov.kh)។

១៣- នៅក្នុង*ក. វ. ស. ៣ឆ្នាំរំកិល* ឆ្នាំមុនៗ (មុន*ក. វ. ស. ៣ឆ្នាំរំកិល២០១១-២០១៣*) ក្រសួងផែនការបានរៀបចំរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង *ក. វ. ស. ៣ឆ្នាំរំកិល*។ ប៉ុន្តែបច្ចុប្បន្ននេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ ដែលរួមមានការវិភាគលើការបន្ស៊ីធនធានដែលបានផ្តល់ជាមួយនឹងការវិភាជតាមវិស័យមានចែងនៅក្នុង*ផ. យ. អ. ជ.*។ ដូច្នេះ *ក. វ. ស. ៣ឆ្នាំរំកិល២០១៩-២០២១* ក៏បន្តមិនដាក់បញ្ចូលនូវរបាយការណ៍វាយតម្លៃលើស្ថានភាពនៃការអនុវត្តគម្រោង*ក. វ. ស. ៣ឆ្នាំរំកិល* ដូចនៅឆ្នាំមុនទៀតដែរ។

១៤- បន្ទាប់ពីសេចក្តីផ្តើមនៃ*ក. វ. ស. ៣ឆ្នាំរំកិល២០១៩-២០២១* នឹងមានបង្ហាញអំពីព័ត៌មានស្តីពីទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩-២០២១ ក្នុងជំពូកទី២។ ជំពូកទី៣ បង្ហាញអំពីព័ត៌មានស្តីពី*ក. វ. ស. ៣ឆ្នាំរំកិល២០១៩-២០២១* និងជំពូកទី៤ បង្ហាញអំពីសេចក្តីសន្និដ្ឋាន។

# ជំពូកទី២

## ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩-២០២១

### ក- ស្ថានភាពទូទៅនៃកំណើនផលិតផលក្នុងស្រុកសរុប២០១៩-២០២១

១៥- ស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរ ហើយកំពុងស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ប្រកបដោយចីរភាពក្នុងរយៈពេលខ្លី និងមធ្យមស្របទៅនឹងការងើបឡើងនៃកំណើនសេដ្ឋកិច្ចពិភពលោកទោះបីកំណើននេះអាចនឹងមានភាពផុយស្រួយ ខណៈដែលស្ថានការណ៍នយោបាយនៃតំបន់មួយចំនួននៅក្នុងពិភពលោកស្ថិតក្នុងភាពមិនច្បាស់លាស់ក៏ដោយ។ ជាលទ្ធផល តាមការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានប្រមាណ៧%នៅឆ្នាំ២០១៧ ដោយសារកំណើនរឹងមាំនៃវិស័យសេវាកម្ម ដែលជួយបំពេញដល់កំណើនយឺតនៃវិស័យកសិកម្មនិងការថមថយបន្តិចនៃវិស័យឧស្សាហកម្ម។ ក្នុងនោះ វិស័យឧស្សាហកម្មនៅតែបន្តកំណើនរឹងមាំទោះបីយឺតជាងមុនបន្តិចក្នុងអត្រាប្រមាណ៩,៩% ហើយនៅតែបន្តដើរតួនាទីជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ចទីមួយ ដែលដឹកមុខដោយវិស័យសំណង់និងគាំទ្រមួយផ្នែកធំពីកំណើនរឹងមាំនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យសេវាកម្មមានភាពល្អប្រសើរក្នុងអត្រាកំណើនប្រមាណ៧,១%ដោយសារការងើបឡើងវិញនៃកំណើននៃវិស័យសណ្ឋាគារនិងភោជនីយដ្ឋាននិងភាពប្រសើរជាងមុននៃវិស័យលក់ដុំនិងលក់រាយ និងវិស័យដឹកញ្ជូន និងទូរគមនាគមន៍ ទោះបីមានកំណើនយឺតក្នុងវិស័យអចលនទ្រព្យ។ ដោយឡែក វិស័យកសិកម្មនៅតែបន្តកំណើនយឺតក្នុងអត្រាប្រមាណ១,៦% ទោះបីអាកាសធាតុត្រូវបានរំពឹងថានឹងប្រសើរជាងមុន ហើយថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិមាននិន្នាការបន្តកើនឡើងក៏ដោយ។ ក្នុងឆ្នាំ២០១៧ ផ.ស.ស.ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់៨៩ ៦៤៧ពាន់លានរៀល ដែលធ្វើឱ្យផ.ស.ស.សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់១ ៤២៧ដុល្លារអាមេរិក។ លើសពីនេះ កម្ពុជាអាចរក្សាបាននូវអតិផរណាដែលស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ដោយអតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថាមានអត្រា២,៩%ក្នុងឆ្នាំ២០១៧ ដោយសារនិន្នាការកើនឡើងនៃថ្លៃប្រេងក្នុងទីផ្សារអន្តរជាតិ។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាព ដោយប្រាក់រៀលមានតម្លៃប្រមាណ៤ ០៤៥រៀលក្នុង១ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ជាមួយនឹងការរំពឹងទុកថាប្រាក់រៀលនឹងនៅបន្តរក្សាបាននូវតម្លៃប្រមាណ៤ ០៣៧រៀលក្នុង១ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។ ការព្យាករអំពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០១៨-២០២១ ត្រូវបានបង្ហាញក្នុងតារាងទី១។

១៦- រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ក្នុងការកាត់បន្ថយគម្លាតចំណូលនិងចំណាយ តាមរយៈការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដើម្បីធានាបានដល់ការបង្កើនប្រសិទ្ធភាពនិងគណនេយ្យភាពនៃការវិភាជថវិកានិងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៤។ ជាក់ស្តែងចំណាយ

របស់រាជរដ្ឋាភិបាលនៅឆ្នាំ២០១៧ មានចំនួន២៣,៦%នៃផ.ស.ស.។ ការអនុវត្តថវិកា បានបង្ហាញឱ្យឃើញនូវការកែទម្រង់ស៊ីជម្រៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះរួមមានការដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ យោធិន នគរបាលជាតិ និងនិវត្តជន ជាពិសេស ជូនគ្រូបង្រៀន និងគ្រូពេទ្យ ទន្ទឹមនឹងធ្វើការកែទម្រង់ ប្រព័ន្ធបៀវត្សរ៍ និងប្រព័ន្ធរដ្ឋបាលសាធារណៈ ហើយប្រការដែលសំខាន់បំផុត គឺការធានាបាននូវការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការបានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ។

**តារាងទី១ : ការព្យាករអំពីសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច**

| សូចនាករសេដ្ឋកិច្ច | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| ផ.ស.ស. (ថ្លៃបច្ចុប្បន្ន-គិតជាពាន់លានរៀល) | ៩៩ ៣៣២ | ១០៩ ៨៩៥ | ១២១ ៥៣១ | ១៣៤ ៥៥៩ |
| ផ.ស.ស. (ថ្លៃបច្ចុប្បន្ន-គិតជាលានដុល្លារអាមេរិក) | ២៤ ៦០៥ | ២៧ ២២២ | ៣០ ១០៤ | ៣៣ ៣៣២ |
| ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (ដុល្លារអាមេរិក) | ១ ៥៦៣ | ១ ៧០៦ | ១ ៨៦២ | ២ ០៣៥ |
| **អត្រាកំណើនពិតនៃផ.ស.ស. (%)** | **៧,០** | **៧,១** | **៧,១** | **៧,២** |
| | | | | |
| អតិផរណា (ការប្រែប្រួលជាមធ្យមប្រចាំឆ្នាំ-គិតជាភាគរយ) | ៣,៤ | ៣,១ | ៣,១ | ៣,២ |
| | | | | |
| **ការវិនិយោគសរុប (%ផ.ស.ស.)** | **២៩,៦** | **២៩,៧** | **២៩,៩** | **៣០,១** |
| ការវិនិយោគសាធារណៈ (%ផ.ស.ស.) | ៧,២ | ៧,២ | ៧,១ | ៧,១ |
| ការវិនិយោគឯកជន (%ផ.ស.ស.) | ២២,៤ | ២២,៦ | ២២,៨ | ២៣,០ |
| | | | | |
| **ចំណូលថវិកាសរុប (%ផ.ស.ស.)** | ១៨,៧ | ១៩,៤ | ១៩,៨ | ២០,១ |
| **ចំណាយថវិកាសរុប (%ផ.ស.ស.)** | ២៤,៥ | ២៤,៥ | ២៤,៥ | ២៤,៦ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨)*

*សម្គាល់ : មានមូលដ្ឋានលើអត្រាប្តូរប្រាក់៤ ០៣៧រៀល =១ដុល្លារអាមេរិក*

១៧- រាជរដ្ឋាភិបាលកម្ពុជាមានផែនការច្បាស់លាស់សម្រាប់ការរៀបចំ*ផ.យ.អ.ជ.២០១៤-២០១៨* គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល ការអប់រំនិងការបណ្តុះបណ្តាលជំនាញ ប្រព័ន្ធដឹកជញ្ជូន និងភស្តុភារ ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យានឹងត្រូវបានពង្រឹងនិងពង្រីកបន្ថែម ដែលជាជំនួយដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដូចជាសហគ្រាសធុនតូចនិងមធ្យមកែច្នៃចំណីអាហារនិងឧស្សាហកម្មរ៉ែ។

## ខ- អត្រាកំណើនផ.ស.ស. ពិត(ថ្លៃថេរឆ្នាំ២000) តាមវិស័យ

១៨- តាមរយៈបទពិសោធដែលទទួលបានពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩និងកិច្ចខិតខំឥតស្រាកស្រាន្តរបស់រាជរដ្ឋាភិបាលគឺយើងសម្រេចបានវិស័យឧស្សាហកម្ម ដែលមានកំណើនពីរខ្ទង់នៅឆ្នាំ២០១០ និងឆ្នាំ២០១១ ដែលក្នុងនោះវិស័យកាត់ដេរក៏មានកំណើនខ្ពស់ពីរខ្ទង់ដូចគ្នាដែលជាមូលដ្ឋានជួយស្តារកំណើនផ. ស. ស. ឡើងវិញនៅឆ្នាំ២០១០និងឆ្នាំ២០១១ បន្ទាប់ពីបានធ្លាក់ចុះនៅឆ្នាំ២០០៩។ ការព្យាករអំពីអត្រាកំណើនផ. ស. ស. ដោយសកម្មភាពសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨-២០២១ ដូចបានបង្ហាញក្នុងតារាងទី២។

**តារាងទី២ : អត្រាកំណើនផ.ស.ស. (ថ្លៃថេរឆ្នាំ២000) តាមវិស័យ**

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| **វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **១, ៨%** | **១, ៨%** | **១, ៦%** | **១, ៦%** |
| ដំណាំ | ២, ២% | ២, ២% | ១, ៧% | ១, ៧% |
| ការចិញ្ចឹមសត្វ | ១, ២% | ១, ៤% | ១, ៧% | ២, ០% |
| ជលផល | ១, ៨% | ២, ១% | ២, ៣% | ២, ៥% |
| ផលព្រៃឈើ | - ០, ៧% | -១, ២% | -១, ២% | -១, ២% |
| **វិស័យឧស្សាហកម្ម** | **៩, ៦%** | **១០, ០%** | **១០, ២%** | **១០, ៤%** |
| វាយនភណ្ឌ, សម្លៀកបំពាក់ និងស្បែកជើង | ៥, ០% | ៥, ១% | ៥, ១% | ៥, ១% |
| សំណង់ | ១៦, ៧% | ១៦, ៩% | ១៦, ៧% | ១៦, ៥% |
| អនុវិស័យឧស្សាហកម្មផ្សេងទៀត | ១១, ៩% | ១២, ២% | ១២, ៣% | ១២, ៣% |
| **វិស័យសេវា** | **៧, ០%** | **៧, ០%** | **៧, ០%** | **៧, ០%** |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៤, ៥% | ៤, ៧% | ៤, ៧% | ៤, ៧% |
| ពាណិជ្ជកម្ម | ៧, ២% | ៧, ៣% | ៧, ៣% | ៧, ៤% |
| អចលនវត្ថុ | ៨, ៤% | ៨, ៥% | ៨, ៤% | ៨, ២% |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៧, ៣% | ៧, ៥% | ៧, ៦% | ៧, ៦% |
| អនុវិស័យសេវាកម្មផ្សេងទៀត | ៦, ៩% | ៦, ៤% | ៦, ៤% | ៦, ៤% |
| **ពន្ធលើផលិតផលដកឧបត្ថម្ភធន** | **៨, ១%** | **៦, ៩%** | **៦, ០%** | **៥, ៤%** |
| **ផលិតផលក្នុងស្រុកសរុប** | **៧, ០%** | **៧, ១%** | **៧, ១%** | **៧, ២%** |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨)*

## គ- ការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.ដែលបានគ្រោងទុក

១៩- គំរូនៃសេដ្ឋកិច្ចវិទ្យាធ្លាប់ប្រើដើម្បីធ្វើការព្យាករអំពីសេដ្ឋកិច្ចសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៩ដល់ ២០១៣ ក៏ត្រូវបានប្រើប្រាស់ដើម្បីធ្វើការព្យាករពីការវិនិយោគសរុបដែលចាំបាច់ក្នុងការធ្វើឱ្យសម្រេចបាន នូវ*កំណើនផ.ស.ស.* ដូចដែលបានគ្រោងទុក និងការបែងចែកនៃការវិនិយោគសរុបទៅតាមវិស័យសេដ្ឋកិច្ច។ ថ្វីបើភាពមានកម្រិតខ្លះពីគំរូនៃសេដ្ឋកិច្ចវិទ្យាក៏ដោយក៏លទ្ធផលនៃការវិភាគបង្ហាញថាទឹកប្រាក់នៃការ វិនិយោគសរុបចំនួន១០៩ ៥១៩,៧ពាន់លានរៀល (២៧ ១២៩លានដុល្លារអាមេរិក) គឺជាតម្រូវការដើម្បី សម្រេចបាននូវកំណើន*ផ.ស.ស.* ដែលបានគ្រោងទុកសម្រាប់ដំណាក់កាលនៃ*ក.វ.ស. ៣ឆ្នាំរំកិល ២០១៩-២០២១* និងតម្រូវការសម្រាប់ឆ្នាំនីមួយៗប្រមាណ២៨ ៥៩៦,២ពាន់លានរៀល (៧ ០៦០,៨លាន ដុល្លារអាមេរិក)។

២០- ប្រភពផ្តល់ហិរញ្ញប្បទានដល់វិនិយោគសរុបចំនួន១០៩ ៥១៩,៧ពាន់លានរៀល (២៧ ១២៩លាន ដុល្លារអាមេរិក) ក្នុងកំលុងពេល *ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* (មានបង្ហាញនៅក្នុងតារាងទី៣)៖

- វិនិយោគមូលធនរបស់វិស័យឯកជននឹងមានប្រមាណ៨៣ ៤៨៩,២ពាន់លានរៀល (២០ ៦៨១,០លានដុល្លារអាមេរិក) សមមូលនឹង៧៦,២% នៃវិនិយោគមូលធនសរុប
- វិនិយោគមូលធនវិស័យសាធារណៈនឹងមានប្រមាណ២៦ ០២៦,៥ពាន់លានរៀល (៦ ៤៤៧,០លានដុល្លារអាមេរិក) សមមូលនឹង២៣,៨% នៃវិនិយោគមូលធនសរុប។

២១- ប្រភពធនធានសម្រាប់តម្រូវការវិនិយោគពីក្នុងស្រុកនិងពីក្រៅប្រទេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ តម្រូវការវិនិយោគមូលធនវិស័យសាធារណៈសរុប២៦ ០២៦,៥ពាន់លានរៀល(៦ ៤៤៧,០លានដុល្លារ អាមេរិក) ក្នុងកំលុងពេល*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* ៖

- ៧ ៦២១,៩ពាន់លានរៀល(១ ៨៨៨,០លានដុល្លារអាមេរិក)សមមូលនឹង២៩,៣%នៃ វិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្នុងស្រុក។
- ១៨ ៤០៤,៧ពាន់លានរៀល(៤ ៥៥៩,០លានដុល្លារអាមេរិក)សមមូលនឹង៧០,៧%នៃ វិនិយោគមូលធនសរុបនឹងត្រូវបានទទួលពីប្រភពក្រៅប្រទេស។

## តារាងទី៣ : ការវិនិយោគចាំបាច់ដើម្បីសម្រេចបានកំណើនផ.ស.ស. ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់

(គិតជាលានដុល្លារអាមេរិក)

| ប្រភពហិរញ្ញប្បទាន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ |
|---|---|---|---|---|---|
| **វិនិយោគមូលធនសរុប** | **៧ ២៨២** | **៨ ០៩៣** | **៨ ៩៩៥** | **១០ ០៤១** | **២៧ ១២៩** |
| • **វិនិយោគមូលធនវិស័យសាធារណៈ** | **១ ៧៨២** | **១ ៩៥៣** | **២ ១៣១** | **២ ៣៦៣** | **៦ ៤៤៧** |
| ➢ ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៥៩៤ | ៥៧៦ | ៦៤២ | ៦៧០ | ១ ៨៨៨ |
| ➢ ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ១ ១៨៨ | ១ ៣៧៨ | ១ ៤៨៨ | ១ ៦៩៣ | ៤ ៥៥៩ |
| • **វិនិយោគមូលធនវិស័យឯកជន** | **៥ ៥០០** | **៦ ១៣៩** | **៦ ៨៦៤** | **៧ ៦៧៨** | **២០ ៦៨១** |
| ➢ ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ២ ៧៥៣ | ៣ ០២៨ | ៣ ៣៤០ | ៣ ៦៨៧ | ១០ ០៥៥ |
| ➢ ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ២ ៧៤៧ | ៣ ១១១ | ៣ ៥២៤ | ៣៩៩១ | ១០ ៦២៦ |
| **វិនិយោគមូលធនសរុប** | **៧ ២៨២** | **៨ ០៩៣** | **៨ ៩៩៥** | **១០ ០៤១** | **២៧ ១២៩** |
| • វិនិយោគមូលធនវិស័យសាធារណៈ | ១ ៧៨២ | ១ ៩៥៣ | ២ ១៣១ | ២ ៣៦៣ | ៦ ៤៤៧ |
| • វិនិយោគមូលធនវិស័យឯកជន | ៥ ៥០០ | ៦ ១៣៩ | ៦ ៨៦៤ | ៧ ៦៧៨ | ២០ ៦៨១ |
| **វិនិយោគមូលធនសរុប** | **៧ ២៨២** | **៨ ០៩៣** | **៨ ៩៩៥** | **១០ ០៤១** | **២៧ ១២៩** |
| • ហិរញ្ញប្បទានដោយធនធានក្នុងស្រុក | ៣ ៣៤៧ | ៣ ៦៤០ | ៣ ៩៨៣ | ៤ ៣៥៧ | ១១ ៩៤៤ |
| • ហិរញ្ញប្បទានដោយធនធានក្រៅប្រទេស | ៣ ៩៣៥ | ៤ ៤៨៩ | ៥ ០១២ | ៥ ៦៨៤ | ១៥ ១៨៥ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨)*

២២- ការបែងចែកលម្អិតនៃការវិនិយោគចាំបាច់ដើម្បីសម្រេចបាននូវកំណើនផ.ស.ស.សរុប ដែលបានគ្រោងទុកតាមរយៈវិស័យសេដ្ឋកិច្ច ត្រូវបានបង្ហាញក្នុងតារាងទី៤។ ដើម្បីសម្រេចបានអត្រាកំណើនផ.ស.ស. សរុប ដែលបានគ្រោងទុកតាមវិស័យ ការវិនិយោគក្នុងក្រុមវិស័យសំខាន់ៗ រួមមានដូចខាងក្រោម÷

- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវការទុនវិនិយោគចំនួន១២ ៦៨៨,៣ពាន់លានរៀល(៣ ១៤៣,០លានដុល្លារអាមេរិក) ដែលផ្តោតជាសំខាន់លើដំណាំស្រូវជាពិសេស ដើម្បី

អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការបង្កើនការនាំអង្ករទៅទីផ្សារអន្តរជាតិ សម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១

- វិស័យឧស្សាហកម្មទូទៅរួមមានការរុករករ៉ែ កម្មន្តសាល អគ្គិសនី ឧស្ម័ន ទឹក និងសំណង់ នឹងត្រូវការទុនវិនិយោគចំនួន៦៧ ៩៧៥,០ពាន់លានរៀល(១៦ ៨៣៨,០លានដុល្លារអាមេរិក) សម្រាប់រយៈពេលក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១។ នៅក្នុងក្រុមនេះ អនុវិស័យកម្មន្តសាល (វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង) នឹងត្រូវការចំណែកធំជាងគេនៃការវិនិយោគ គឺមានចំនួនប្រមាណ១៣ ៦៥៣,១ពាន់លានរៀល(៣ ៣៨២,០លានដុល្លារអាមេរិក) និងអនុវិស័យសំណង់ត្រូវការចំណែកធំនៃការវិនិយោគ គឺមានចំនួន៤៧ ៤៩៩,៣ពាន់លានរៀល(១១ ៧៦៦,០លានដុល្លារអាមេរិក) ហើយអនុវិស័យអគ្គិសនី ឧស្ម័ន និងទឹកត្រូវការទុនវិនិយោគចំនួនប្រមាណ ៦ ៤៣៩,០ពាន់លានរៀល(១ ៥៩៥,០លានដុល្លារអាមេរិក)
- វិស័យសេវារួមមានពាណិជ្ជកម្ម សណ្ឋាគារ និងភោជនីយដ្ឋាន(ទេសចរណ៍) ដឹកជញ្ជូន និងទូរគមនាគមន៍ ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ និងអចលនទ្រព្យត្រូវការទុនវិនិយោគចំនួន ៣៣ ៩២៦,៩ពាន់លានរៀល(៨ ៤០៤,០លានដុល្លារអាមេរិក)។

**តារាងទី៤ៈ វិនិយោគមូលធនដែលត្រូវការតាមវិស័យនីមួយៗដើម្បីសម្រេចបាននូវគោលដៅកំណើនផ.ស.ស.**

(គិតជាលានដុល្លារអាមេរិក)

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២១ |
|---|---|---|---|---|---|
| **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **៩២០** | **៩៩១** | **១ ០៤៥** | **១ ១០៧** | **៣ ១៤៣** |
| ដំណាំ | ៧៧៦ | ៨៣៥ | ៨៩៦ | ៩៤៩ | ២ ६៨០ |
| បសុសត្វនិងបសុបក្សី | ៤៥ | ៤៩ | ៤០ | ៤៣ | ១៣២ |
| ជលផល | ៦១ | ៦៧ | ៧០ | ៧៥ | ២១២ |
| ផលព្រៃឈើ | ៣៨ | ៤០ | ៣៩ | ៤០ | ១១៩ |
| **ឧស្សាហកម្ម** | **៤ ០១៣** | **៤ ៥៣៦** | **៥ ៦៧៧** | **៦ ៦២៥** | **១៦ ៨៣៨** |
| រ៉ែ | ២៥ | ២៨ | ៣១ | ៣៥ | ៩៤ |
| កម្មន្តសាល | ៨៧២ | ៩៨៦ | ១ ១២០ | ១ ២៧៦ | ៣ ៣៨២ |
| អាហារនិងភេសជ្ជៈនិងថ្នាំជក់ | ៧៧ | ៨៣ | ៩០ | ៩៨ | ២៧១ |
| វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | ៤១៨ | ៤៥២ | ៤៩០ | ៥៣១ | ១ ៤៧៣ |
| ឈើ ក្រដាស និងការបោះពុម្ព | ៣៥ | ៣៨ | ៤១ | ៤៤ | ១២៣ |

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២១ |
|---|---|---|---|---|---|
| កម្មន្តសាលកៅស៊ូ | ៥៤ | ៥៨ | ៦៣ | ៦៨ | ១៨៩ |
| កម្មន្តសាលផ្សេងៗទៀត | ២៨៩ | ៣៥៥ | ៤៣៥ | ៥៣៥ | ១ ៣២៥ |
| អគ្គិសនី ឧស្ម័ន និងទឹក | ៣៣២ | ៣៦៣ | ៥០៨ | ៧២៤ | ១ ៥៩៥ |
| សំណង់ | ២ ៧៨៤ | ៣ ១៥៨ | ៤ ០១៨ | ៤ ៥៩០ | ១១ ៧៦៦ |
| **សេវា** | **២៣៥០** | **២៥៦៦** | **២៧៩២** | **៣០៤៧** | **៨ ៤០៤** |
| ពាណិជ្ជកម្ម | ៤០៥ | ៤៤២ | ៤៨២ | ៥២៦ | ១ ៤៥០ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ២៧៤ | ២៨៨ | ៣០២ | ៣១៧ | ៩០៧ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៦០៣ | ៦៦៣ | ៧២២ | ៧៩៤ | ២ ១៧៩ |
| ហិរញ្ញវត្ថុ | ៨២ | ៩០ | ៩៩ | ១០៩ | ២៩៨ |
| រដ្ឋបាលសាធារណៈ | ៥០៦ | ៥៥៤ | ៦០៤ | ៦៥៨ | ១ ៨១៦ |
| អចលនវត្ថុនិងធុរកិច្ច | ២៩៨ | ៣២៩ | ៣៦២ | ៣៩៨ | ១ ០៨៩ |
| សេវាផ្សេងៗទៀត | ១៨២ | ២០០ | ២២០ | ២៤៤ | ៦៦៤ |
| **សរុប** | **៧ ២៨២** | **៨ ០៩៣** | **៩ ៥១៥** | **១០ ៧៧៨** | **២៨ ៣៨៦** |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨)*

## ឃ- ចំណូលនិងចំណាយថវិកា ២០១៩-២០២១

២៣- ចំណូលក្នុងស្រុករបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០១៧ត្រូវបានអនុវត្តមានចំនួនប្រហែល២០,០៧% នៃផ.ស.ស.។ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូល រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មីឬដំឡើងពន្ធបន្ថែមដល់ប្រជាជននិងធុរជននោះទេ ពោលគឺរាជរដ្ឋាភិបាលបានផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយនិងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាលនិងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ជាពិសេស ការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ។ ជាមួយនឹងវិធានការទាំងនេះ ចំណូលក្នុងស្រុកសរុបរបស់រាជរដ្ឋាភិបាល គ្រោងនឹងសម្រេចបាន១៨,៧%នៃផ.ស.ស. ក្នុងឆ្នាំ២០១៨ នឹង១៩,៤% សម្រាប់ឆ្នាំ២០១៩។

២៤- តាមរយៈការអនុវត្តចំណាយថវិកាសរុបជាសមាមាត្រនៃផ.ស.ស.សរុបបានកើនឡើងពី២០,៩% ក្នុងឆ្នាំ២០១៥ដល់២៣,៦%ក្នុងឆ្នាំ២០១៧។ រាជរដ្ឋាភិបាលបាននិងកំពុងបន្តការអនុវត្តគោលនយោបាយ

ជំរុញកំណើននិងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ចជាមួយនឹងការខិតខំប្រឹងប្រែងធានាឱ្យបាននូវប្រសិទ្ធផលនិងប្រសិទ្ធភាពចំណាយ ជាពិសេស ការចំណាយសម្រាប់កម្មវិធីកាត់បន្ថយភាពក្រីក្រនិងការផ្តោតសំខាន់លើវិស័យអាទិភាពនានា ដូចជាវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈវិស័យសុខាភិបាល វិស័យកសិកម្មក៏ដូចជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។ ក្នុងន័យនេះចំណាយថវិកាសរុបត្រូវបានប៉ាន់ស្មានថានឹងកើនឡើងពី២៤,២%នៃផ. ស. ស. ក្នុងឆ្នាំ២០១៨ដល់២៤,៥%នៃផ. ស. ស. ក្នុងឆ្នាំ២០១៩។

២៥- ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងអនុវត្តយន្តការចំនួន២ គឺក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម (អភិក្រមពីលើចុះក្រោម) និងផែនការយុទ្ធសាស្ត្រថវិកា(អភិក្រមពីក្រោមទៅលើ) ដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយគឺ*ក្របខ័ណ្ឌចំណាយសម្រាប់រយៈមធ្យម* ដែលព្យាករពីតួលេខចំណាយចរន្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។ ការព្យាករនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ។ ការព្យាករផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ចគោលនយោបាយអាទិភាព ក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទីពីរគឺ*ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកាសម្រាប់រយៈពេល៣ឆ្នាំ* ដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើ។ ធាតុចូលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះផ្អែកលើព័ត៌មានដែលប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងព័ត៌មានស្តីពីចំណាយនិងតម្រូវការរយៈពេល៣ឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរដើម្បីកែលម្អការរៀបចំថវិកាប្រចាំឆ្នាំ។

## ខ- ចំណុចដៅនៃការកៀរគរធនធានសម្រាប់ការវិនិយោគរបស់វិស័យសាធារណៈឆ្នាំ២០១៤-២០១៨

២៦- រាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈដែលអាចមានតម្លៃប្រមាណ៤៥ ៥១១,៩ពាន់លានរៀល(១១ ២៧៣,៧លានដុល្លារអាមេរិក) ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា។ តម្លៃប៉ាន់ស្មាននេះរួមបញ្ចូលនូវ÷ *(១)* តម្រូវការវិនិយោគមូលធនសម្រាប់វិស័យសាធារណៈដែលអាចមានប្រមាណ៣០ ៦៨១,២ពាន់លានរៀល (៧ ៦០០លានដុល្លារអាមេរិក) *(២)* ធនធានដែលត្រូវការជាចាំបាច់ដើម្បីផ្តល់ការគាំទ្រដែលមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍ ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទសំដៅកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល និងការផ្តល់ការគាំទ្របន្ទាន់ដល់ការសម្រាលផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុសកលលោក និងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោកទៅលើប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះដែលអាចមានប្រមាណ៧ ៤៤៣,៨ពាន់លានរៀល(១ ៨៤៣,៩លានដុល្លារអាមេរិក) *(៣)* ធនធានដែល

ត្រូវការជាចាំបាច់ ដើម្បីពង្រីកសេវាសង្គមកិច្ចសំដៅឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព* ដែលអាចមានប្រមាណ៣ ៧២៣,៨ ពាន់លានរៀល(៩២២,៤លានដុល្លារអាមេរិក) និង*(៤)* ធនធានដែលត្រូវការជាចាំបាច់ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតកម្មវិធីនិងការផ្តល់នូវសេវាប្រកបដោយប្រសិទ្ធភាព ដែលអាចមានប្រមាណ៣ ៧២៣,៨ពាន់លានរៀល(៩២២,៤លានដុល្លារអាមេរិក)។

**តារាងទី៥ : ចំណុចដៅនៃការគៀរគរធនធានសម្រាប់វិនិយោគរបស់វិស័យសាធារណៈ ឆ្នាំ២០១៩-២០២១**

| តម្រូវការវិនិយោគវិស័យសាធារណៈ | ២០១៩-២០២១ | |
|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក |
| ១- វិនិយោគមូលធនរបស់វិស័យសាធារណៈ (ការព្យាករម៉ាក្រូសេដ្ឋកិច្ច) | ២៦ ០២៦,៥៤ | ៦ ៤៤៧,០ |
| ២- ការគាំទ្រមានគោលដៅច្បាស់លាស់ដល់ការអភិវឌ្ឍនិងពិពិធកម្មសេដ្ឋកិច្ចជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល | ៤ ៤៦៦,១៣ | ១ ១០៦,៣ |
| ៣- ការពង្រីកសេវាសង្គមកិច្ច ដើម្បីឈានទៅសម្រេចបាននូវចំណុចដៅទាំងឡាយនៃគ.អ.ស.ក. ឬគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ២ ២៣៤,៤៨ | ៥៥៣,៥ |
| ៤- ការគាំទ្រដល់ការពង្រឹងសមត្ថភាពនៃស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតកម្មវិធីនិងការផ្តល់សេវាកម្ម ប្រកបដោយប្រសិទ្ធភាព | ២ ២៣៤,៤៨ | ៥៥៣,៥ |
| សរុប | ៣៤ ៩៦១,៦៣ | ៨ ៦៦០,៣ |

*ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងផែនការ*

២៧- សម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* គឺត្រូវការថវិកាសរុបប្រមាណ២៦ ០២៦,៥ពាន់លានរៀល(៦ ៤៤៧,០លានដុល្លារអាមេរិក)ឬប្រមាណ៨ ៦៦៩,១ពាន់លានរៀល(២ ១៤៩លានដុល្លារអាមេរិក) ក្នុងមួយឆ្នាំ។ បរិមាណថវិកាសរុបសម្រាប់អនុវត្ត*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* ប្រមាណ២៦ ០២៦,៥ ពាន់លានរៀល(៦ ៤៤៧,០លានដុល្លារអាមេរិក) ដែលក្នុងនោះហិរញ្ញប្បទានក្នុងស្រុកដោយរាជរដ្ឋាភិបាលមាន៧ ៦២១,៩ពាន់លានរៀល(១ ៨៨៨,០លានដុល្លារអាមេរិក) និងចំណែកដែលនៅសល់១៨ ៤០៤,៧ ពាន់លានរៀល(៤ ៥៥៩,០លានដុល្លារអាមេរិក) ឬប្រមាណ៦ ១៣៥,០ពាន់លានរៀល(១ ៥១៩,៧លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចត្រូវបានធ្វើហិរញ្ញប្បទានពីប្រភពដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីដៃគូអភិវឌ្ឍ ទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល)
- កម្ចីសម្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេស(ភាគច្រើនពីស្ថាប័នហិរញ្ញវត្ថុពហុភាគីនិងទ្វេភាគី)
- ចំណូលថ្មីៗដែលអាចបានមកពីការអភិវឌ្ឍឧស្សាហកម្មអាជីវកម្មរ៉ែ។

២៨- រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដែលមានប្រមាណ១៨ ៤០៤,៧ពាន់លានរៀល(៤ ៥៥៩,០លានដុល្លារអាមេរិក) ឬប្រមាណ៦ ១៣៥,០ពាន់លានរៀល (១ ៥១៩,៧លានដុល្លារអាមេរិក)ក្នុងមួយឆ្នាំ អាចនឹងទទួលបានពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍនិងពីចំណូលបន្ថែមថ្មីពីប្រេង ឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម។ ក៏ប៉ុន្តែការកៀរគរហិរញ្ញប្បទានបន្ថែមពីដៃគូ ដូចជាមិនបានបង្ហាញពីភាពងាយស្រួលឡើយ ដោយសារដៃគូអភិវឌ្ឍភាគច្រើនបានសន្យាផ្តល់រួចមកហើយនិងដើម្បីសម្រេចបានហិរញ្ញប្បទានគ្រប់ចំនួន គឺត្រូវខិតខំស្វែងរកបន្ថែមទៀតនូវដៃគូអភិវឌ្ឍថ្មីផ្សេងៗទៀត។ សម្រាប់រាជរដ្ឋាភិបាល គឺត្រូវពិនិត្យឱ្យច្បាស់លាស់នូវកំណែទម្រង់សេដ្ឋកិច្ច ដូចជាការបង្កើនទិន្នផលស្រូវនិងការនាំចេញ និងការធ្វើពិពិធកម្មដំណាំផ្សេងៗក្រៅពីដំណាំស្រូវ ជាពិសេស សម្រាប់អនាគត ត្រូវគ្រប់គ្រងចំណូលទទួលបានពីអាជីវកម្មរ៉ែ ដីសម្បទាន និងចំណូលពន្ធ។

២៩- ការបែងចែកតាមវិស័យនិងអនុវិស័យនៃតម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ សម្រាប់ឆ្នាំ ២០១៩-២០២១ នៅក្នុងតារាងទី៦ខាងក្រោម គឺមានមូលដ្ឋានពីការបែងចែកតាមវិស័យនិងអនុវិស័យ ចែងនៅក្នុងតារាងទី៥.៣ នៃ*ផ.យ.អ.ជ. ២០១៤-២០១៨*។

**តារាងទី៦ : ការបែងចែកតាមវិស័យនិងអនុវិស័យសម្រាប់តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដោយមានមូលដ្ឋានពីការបែងចែកតាមវិស័យនិងអនុវិស័យចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨**

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០១៩-២០២១ | |
|---|---|---|---|
| | | ពាន់លានរៀល | លានដុល្លារអាមេរិក |
| **វិស័យសង្គមកិច្ច** | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១២ | ៣ ៦៨១,៧៤ | ៩១២,០ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| សុខាភិបាល | ១២ | ៣ ៦៨១,៧៤ | ៩១២,០ |
| កម្មវិធីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| សរុប | ៣២ | ៩ ៨១៧,៩៨ | ២ ៤៣២,០ |
| **វិស័យសេដ្ឋកិច្ច** | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៣ ៦៨១,៧៤ | ៩១២,០ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| សរុប | ២៤ | ៧ ៣៦៣,៤៩ | ១ ៨២៤,០ |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | |

| | | | |
|---|---|---|---|
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ៣ ៦៨១,៧៤ | ៩១២,០ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| ថាមពលនិងអគ្គិសនី | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៣០៦,៨១ | ៧៦,០ |
| សរុប | ២១ | ៦ ៤៤៣,០៥ | ១ ៥៩៦,០ |
| **សេវាកម្មនិងកម្មវិធីអន្តរវិស័យ** | | | |
| ការបញ្ច្រាបយេនឌ័រ | ១,៥ | ៤៦០,២២ | ១១៤,០ |
| ទេសចរណ៍ | ២ | ៦១៣,៦២ | ១៥២,០ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ១ ២២៧,២៥ | ៣០៤,០ |
| វប្បធម៌និងសិល្បៈ | ១,៥ | ៤៦០,២២ | ១១៤,០ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ២ ៤៥៤,៥០ | ៦០៨,០ |
| សរុប | ២១ | ៦ ៤៤៣,០៥ | ១ ៥៩៦,០ |
| **មិនទាន់បែងចែក** | **២** | **៦១៣,៦២** | **១៥២,០** |
| **សរុបរួម** | **១០០** | **៣០ ៦៨១,០** | **៧ ៦០០,០** |

*ប្រភព : ផ.យ.អ.ជ.២០១៤-២០១៨*

# ជំពូកទី៣

## កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៩-២០២១

៣០- ដូចបានបង្ហាញក្នុងជំពូកមុនដែរ សម្រាប់ការអនុវត្ត*ផ.យ.អ.ជ. ២០១៤-២០១៨*(រយៈពេល៥ឆ្នាំ) រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប៉ាន់ស្មានតម្លៃសរុបចំនួន៣០ ៦៨១,២ពាន់លានរៀល(៧ ៦០០លានដុល្លារអាមេរិក) សម្រាប់បំពេញតម្រូវការវិនិយោគវិស័យសាធារណៈ ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៥។ ការវិភាជសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* មានចំនួន២៦ ០២៦,៥ពាន់លានរៀល(៦ ៤៤៧,០លានដុល្លារអាមេរិក) (តារាងទី៧) និងដូចមានចែងនៅក្នុងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម គឺរាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាជាតិចំនួន៧ ៦២១,៨ ពាន់លានរៀល(១ ៨៨៨,០លានដុល្លារអាមេរិក) សម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១*។

### តារាងទី៧ : ការវិភាជតាមវិស័យនិងអនុវិស័យ សម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈ ចែងនៅក្នុងផ.យ.អ.ជ. ២០១៤-២០១៨ និងក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១

| វិស័យ និងអនុវិស័យ | គោលដៅវិនិយោគសាធារណៈក្នុងផ.យ.អ.ជ. ២០១៤-២០១៨ | | | | | |
|---|---|---|---|---|---|---|
| | ផ.យ.អ.ជ. ២០១៤-២០១៨ | | | ក.វ.ស. ២០១៩-២០២១ | | |
| | ភាគរយ | ពាន់លានរៀល | លានដុល្លារអាមេរិក | ពាន់លានរៀល | លានដុល្លារអាមេរិក | ភាគរយ |
| **វិស័យសង្គមកិច្ច** | | | | | | |
| អប់រំ : ក្នុងនោះការអប់រំមូលដ្ឋាន៦០% | ១២ | ៣ ៦៨១,៧៤ | ៩១២,០ | ៣ ១២៣,១៨ | ៧៧៣,៦៤ | ១២ |
| បច្ចេកទេសនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| សុខាភិបាល | ១២ | ៣ ៦៨១,៧៤ | ៩១២,០ | ៣ ១២៣,១៨ | ៧៧៣,៦៤ | ១២ |
| កម្មវិធីជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្ដាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោកលើជនងាយរងគ្រោះនិងអ្នកក្រ | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| សរុប | ៣២ | ៩ ៨១៧,៩៨ | ២ ៤៣២,០ | ៨ ៣២៨,៤៩ | ២ ០៦៣,០៤ | ៣២ |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| ដំណាំតាមរដូវ : ស្រូវនិងដំណាំផ្សេងៗ | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| អភិវឌ្ឍន៍ជនបទ | ១២ | ៣ ៦៨១,៧៤ | ៩១២,០ | ៣ ១២៣,១៨ | ៧៧៣,៦៤ | ១២ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| សរុប | ២៤ | ៧ ៣៦៣,៤៩ | ១ ៨២៤,០ | ៦ ២៤៦,៣៧ | ១ ៥៤៧,២៨ | ២៤ |

| | | | | | | |
|---|---|---|---|---|---|---|
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ៣ ៦៨១,៧៤ | ៩១២,០ | ៣ ១២៣,១៨ | ៧៧៣,៦៤ | ១២ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| ថាមពលនិងអគ្គិសនី | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ៣០៦,៨១ | ៧៦,០ | ២៦០,២៧ | ៦៤,៤៧ | ១ |
| សរុប | **២១** | **៦ ៤៤៣,០៥** | **១ ៥៩៦,០** | **៥ ៤៦៥,៥៧** | **១ ៣៥៣,៨៧** | **២១** |
| **សេវានិងកម្មវិធីអន្តរវិស័យ** | | | | | | |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ៤៦០,២២ | ១១៤,០ | ៣៩០,៤០ | ៩៦,៧១ | ១,៥ |
| ទេសចរណ៍ | ២ | ៦១៣,៦២ | ១៥២,០ | ៥២០,៥៣ | ១២៨,៩៤ | ២ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ១ ២២៧,២៥ | ៣០៤,០ | ១ ០៤១,០៦ | ២៥៧,៨៨ | ៤ |
| វប្បធម៌និងសិល្បៈ | ១,៥ | ៤៦០,២២ | ១១៤,០ | ៣៩០,៤០ | ៩៦,៧១ | ១,៥ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ២ ៤៥៤,៥០ | ៦០៨,០ | ២ ០៨២,១២ | ៥១៥,៧៦ | ៨ |
| សរុប | **២១** | **៦ ៤៤៣,០៥** | **១ ៥៩៦,០** | **៥ ៤៦៥,៥៧** | **១ ៣៥៣,៨៧** | **២១** |
| **មិនទាន់បែងចែក** | **២** | **៦១៣,៦២** | **១៥២,០** | **៥២០,៥៣** | **១២៨,៩៤** | **២** |
| សរុបរួម | ១០០ | ៣០ ៦៨១,០ | ៧ ៦០០,០ | **២៦ ០២៦,៥៤** | **៦ ៤៤៧,០** | ១០០ |

*ប្រភព៖ ផ.យ.អ.ជ. ២០១៤-២០១៨*

## ក- សេចក្តីសង្ខេបនៃគម្រោងសម្រាប់ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១ ដែលបានទទួលពីក្រសួង ស្ថាប័ន

៣១- *ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* បានរៀបចំឡើងដោយមានមូលដ្ឋានលើធាតុចូលដែលបានទទួលពីគ្រប់ក្រសួង ស្ថាប័ន រួមមាន÷ *(១) គម្រោងកំពុងដំណើរការ* ជាគម្រោងដែលកំពុងអនុវត្តដោយមានកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង*(២) គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(គម្រោងថ្មី)* ដែលក្រសួង ស្ថាប័ន មានគម្រោងអនុវត្តក្នុងកំលុងពេលឆ្នាំ២០១៩-២០២១។ *ផ.យ.អ.ជ. ២០១៤-២០១៨* បានចែងថាបរិមាណថវិកាចំនួន៧ ៦០០,០លានដុល្លារអាមេរិក នឹងត្រូវចំណាយសម្រាប់តម្រូវការវិនិយោគវិស័យសាធារណៈសម្រាប់រយៈពេល៥ឆ្នាំ២០១៤-២០១៨ ចំណែកឯតម្រូវការវិនិយោគវិស័យសាធារណៈនៃ *ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* មានចំនួន៦ ៤៤៧,០លានដុល្លារអាមេរិក។ ព័ត៌មានសង្ខេបស្តីពីគម្រោង*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* ដែលបានស្នើឡើងដោយក្រសួង ស្ថាប័នមានបង្ហាញនៅក្នុងតារាងទី៨÷

- តម្រូវការចំណាយប៉ាន់ស្មានសរុបសម្រាប់*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* តម្រូវការថវិកាសរុប៦ ៤៤៧,០លានដុល្លារអាមេរិក។
  - គម្រោងកំពុងដំណើរការ ៣ ៦៦១,០លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.(ថ្មី) ២ ៧៨៦,០លានដុល្លារអាមេរិក
- បរិមាណថវិកាដែលក្រសួង ស្ថាប័នបានរាយការណ៍ថា បានសន្យាផ្តល់៤ ០៩៣,២លានដុល្លារអាមេរិក
  - ថវិកាជាតិ ៤៥៧,០លានដុល្លារអាមេរិក
  - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៣ ៦៣៦,២លានដុល្លារអាមេរិក
    - សម្រាប់គម្រោងកំពុងដំណើរការ ៣ ៤៤៣,៦លានដុល្លារអាមេរិក
      - ថវិកាជាតិ ៣៧៤,៣លានដុល្លារអាមេរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៣ ០៦៩,៤លានដុល្លារអាមេរិក
    - សម្រាប់គម្រោងអនុវត្តផ.យ.អ.ជ.(ថ្មី) ៦៤៩,៦លានដុល្លារអាមេរិក
      - ថវិកាជាតិ ៨២,៨លានដុល្លារអាមេរិក
      - ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ៥៦៦,៨លានដុល្លារអាមេរិក
- តម្រូវការថវិកាបំពេញបន្ថែម(បំពេញបន្ថែមលើបរិមាណហិរញ្ញប្បទានដែលបានសន្យា) ២ ៣៥៣,៨លានដុល្លារអាមេរិក
  - គម្រោងកំពុងដំណើរការ ២១៧,៣លានដុល្លារអាមេរិក
  - គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ២ ១៣៦,៤លានដុល្លារអាមេរិក

៣២- តារាងទី៩នឹងធ្វើការបង្ហាញលម្អិតបន្ថែមនូវគម្រោងដែលក្រសួង ស្ថាប័នទាំងអស់បានផ្ញើមកក្រសួងផែនការសម្រាប់ធ្វើការរៀបចំ*ក.វ.ស. ៣ឆ្នាំរំកិល២០១៩-២០២១* និងបានបែងចែកគម្រោងទាំងអស់នោះទៅតាមវិស័យអាទិភាពរបស់*ផ.យ.អ.ជ. ២០១៤-២០១៨* ។ ព័ត៌មានគម្រោងទាំងនោះរួមមាន (១) តម្រូវការចំណាយប៉ាន់ស្មានសរុបទៅតាមឆ្នាំនីមួយៗពីឆ្នាំ២០១៩-២០២១ (២) បរិមាណហិរញ្ញប្បទានដែលក្រសួង ស្ថាប័នបានរាយការណ៍ថាបានសន្យាផ្តល់(ដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ) សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. និង(៣) បរិមាណតម្រូវការហិរញ្ញប្បទានបំពេញបន្ថែមលើហិរញ្ញប្បទានដែលបានសន្យាផ្តល់រួចហើយក្នុងឆ្នាំនីមួយៗ។

## តារាងទី៨ : សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ដែលក្រសួង ស្ថាប័នស្នើសុំសម្រាប់ក.ទ.ស. ៣ឆ្នាំរំកិល២០១៩-២០២១

(គិតជាពាន់ដុល្លារអាមេរិក)

| | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ | ប្រភពហិរញ្ញប្បទាន | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ |
| គម្រោងកំពុងដំណើរការ | | | | | រាជរដ្ឋាភិបាល | 159,879.4 | 115,802.0 | 98,579.8 | 374,261.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 1,178,923.5 | 1,100,762.1 | 789,716.9 | 3,069,402.5 | | | | |
| | 1,392,000.0 | 1,297,000.0 | 972,000.0 | 3,661,000.0 | សរុប | 1,338,802.9 | 1,216,564.1 | 888,296.7 | 3,443,663.7 | 53,197.1 | 80,435.9 | 83,703.3 | 217,336.3 |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | | | | | រាជរដ្ឋាភិបាល | 39,519.3 | 21,877.1 | 21,365.8 | 82,762.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 150,101.2 | 211,207.6 | 205,497.2 | 566,806.0 | | | | |
| | 747,000.0 | 857,000.0 | 1,182,000.0 | 2,786,000.0 | សរុប | 189,620.5 | 233,084.7 | 226,863.0 | 649,568.2 | 557,379.5 | 623,915.3 | 955,137.0 | 2,136,431.8 |
| សរុប | | | | | រាជរដ្ឋាភិបាល | 199,398.7 | 137,679.1 | 119,945.6 | 457,023.4 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 1,329,024.7 | 1,311,969.7 | 995,214.1 | 3,636,208.5 | | | | |
| | 2,139,000.0 | 2,154,000.0 | 2,154,000.0 | 6,447,000.0 | សរុប | 1,528,423.4 | 1,449,648.8 | 1,115,159.7 | 4,093,231.9 | 610,576.6 | 704,351.2 | 1,038,840.3 | 2,353,768.1 |

## តារាងទី៩ : សេចក្តីសង្ខេបស្តីពីគម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. បែងចែកទៅតាមវិស័យអាទិភាពនៃ២០១៤-២០១៨ ដែលក្រសួង ស្ថាប័នស្នើសុំ

(គិតជាពាន់ដុល្លារអាមេរិក)

| ក្រសួង ស្ថាប័ន | ចំណាយប៉ាន់ស្មានសរុប | | | | ហិរញ្ញប្បទានបានសន្យាផ្តល់ | | | | | តម្រូវការហិរញ្ញប្បទានបំពេញបន្ថែម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ | ប្រភពហិរញ្ញប្បទាន | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ | ២០១៩ | ២០២០ | ២០២១ | សរុប ២០១៩-២០២១ |
| **វិស័យសង្គមកិច្ច** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 282,741.2 | 226,346.2 | 176,853.5 | 685,940.9 | សរុប | 239,726.8 | 179,465.8 | 109,451.0 | 528,643.6 | 43,014.4 | 46,880.4 | 67,402.5 | 157,297.3 |
| | | | | | រាជរដ្ឋាភិបាល | 42,924.8 | 14,699.4 | 13,175.8 | 70,800.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 196,802.0 | 164,766.4 | 96,275.2 | 457,843.6 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 31,765.9 | 30,942.8 | 30,177.8 | 92,886.5 | សរុប | 28,861.9 | 28,861.9 | 28,861.9 | 86,585.7 | 2,904.0 | 2,080.9 | 1,315.9 | 6,300.8 |
| | | | | | រាជរដ្ឋាភិបាល | 15,965.9 | 15,965.9 | 15,965.9 | 47,897.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 12,896.0 | 12,896.0 | 12,896.0 | 38,688.0 | | | | |
| សរុប | 314,507.1 | 257,289.0 | 207,031.3 | 778,827.4 | សរុប | 268,588.7 | 208,327.7 | 138,312.9 | 615,229.3 | 45,918.4 | 48,961.3 | 68,718.4 | 163,598.1 |
| | | | | | រាជរដ្ឋាភិបាល | 58,890.7 | 30,665.3 | 29,141.7 | 118,697.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 209,698.0 | 177,662.4 | 109,171.2 | 496,531.6 | | | | |
| ១.ក្រសួងសុខាភិបាល | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 114,184.9 | 79,649.9 | 67,675.0 | 261,509.8 | សរុប | 75,370.5 | 37,369.5 | 8,672.5 | 121,412.5 | 38,814.4 | 42,280.4 | 59,002.5 | 140,097.3 |
| | | | | | រាជរដ្ឋាភិបាល | 27,905.6 | 9,800.4 | 8,422.5 | 46,128.5 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ដៃគូអភិវឌ្ឍ | 47,464.9 | 27,569.1 | 250.0 | 75,284.0 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 350.4 | 359.4 | 359.4 | 1,069.2 | សរុប | 25.0 | 25.0 | 25.0 | 75.0 | 325.4 | 334.4 | 334.4 | 994.2 |
| | | | | | រាជរដ្ឋាភិបាល | 25.0 | 25.0 | 25.0 | 75.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| សរុប | 114,535.3 | 80,009.3 | 68,034.4 | 262,579.0 | សរុប | 75,395.5 | 37,394.5 | 8,697.5 | 121,487.5 | 39,139.8 | 42,614.8 | 59,336.9 | 141,091.5 |
| | | | | | រាជរដ្ឋាភិបាល | 27,930.6 | 9,825.4 | 8,447.5 | 46,203.5 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 47,464.9 | 27,569.1 | 250.0 | 75,284.0 | | | | |
| ២.ក្រសួងអប់រំ យុវជន និងកីឡា | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 146,456.3 | 124,096.3 | 86,178.5 | 356,731.1 | សរុប | 146,456.3 | 124,096.3 | 86,178.5 | 356,731.1 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | រាជរដ្ឋាភិបាល | 10,719.2 | 499.0 | 453.3 | 11,671.5 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 135,737.1 | 123,597.3 | 85,725.2 | 345,059.6 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 12,896.0 | 12,896.0 | 12,896.0 | 38,688.0 | សរុប | 12,896.0 | 12,896.0 | 12,896.0 | 38,688.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | រាជរដ្ឋាភិបាល | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 12,896.0 | 12,896.0 | 12,896.0 | 38,688.0 | | | | |
| សរុប | 159,352.3 | 136,992.3 | 99,074.5 | 395,419.1 | សរុប | 159,352.3 | 136,992.3 | 99,074.5 | 395,419.1 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | រាជរដ្ឋាភិបាល | 10,719.2 | 499.0 | 453.3 | 11,671.5 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 148,633.1 | 136,493.3 | 98,621.2 | 383,747.6 | | | | |
| ៣.ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 0.0 | 0.0 | 0.0 | 0.0 | សរុប | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | រាជរដ្ឋាភិបាល | 0.0 | 0.0 | 0.0 | 0.0 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 18,519.5 | 17,687.4 | 16,922.4 | 53,129.3 | សរុប | 15,940.9 | 15,940.9 | 15,940.9 | 47,822.7 | 2,578.6 | 1,746.5 | 981.5 | 5,306.6 |
| | | | | | រាជរដ្ឋាភិបាល | 15,940.9 | 15,940.9 | 15,940.9 | 47,822.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| សរុប | 18,519.5 | 17,687.4 | 16,922.4 | 53,129.3 | សរុប | 15,940.9 | 15,940.9 | 15,940.9 | 47,822.7 | 2,578.6 | 1,746.5 | 981.5 | 5,306.6 |
| | | | | | រាជរដ្ឋាភិបាល | 15,940.9 | 15,940.9 | 15,940.9 | 47,822.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| ៤.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 22,100.0 | 22,600.0 | 23,000.0 | 67,700.0 | សរុប | 17,900.0 | 18,000.0 | 14,600.0 | 50,500.0 | 4,200.0 | 4,600.0 | 8,400.0 | 17,200.0 |
| | | | | | រាជរដ្ឋាភិបាល | 4,300.0 | 4,400.0 | 4,300.0 | 13,000.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 13,600.0 | 13,600.0 | 10,300.0 | 37,500.0 | | | | |
| គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. | 0.0 | 0.0 | 0.0 | 0.0 | សរុប | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | រាជរដ្ឋាភិបាល | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| សរុប | 22,100.0 | 22,600.0 | 23,000.0 | 67,700.0 | សរុប | 17,900.0 | 18,000.0 | 14,600.0 | 50,500.0 | 4,200.0 | 4,600.0 | 8,400.0 | 17,200.0 |
| | | | | | រាជរដ្ឋាភិបាល | 4,300.0 | 4,400.0 | 4,300.0 | 13,000.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 13,600.0 | 13,600.0 | 10,300.0 | 37,500.0 | | | | |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | | | | |
| គម្រោងកំពុងដំណើរការ | 614,571.6 | 584,664.4 | 388,184.3 | 1,587,420.3 | សរុប | 606,990.9 | 559,833.4 | 372,422.9 | 1,539,247.2 | 7,580.7 | 24,831.0 | 15,761.4 | 48,173.1 |
| | | | | | រាជរដ្ឋាភិបាល | 85,358.2 | 82,067.6 | 80,877.4 | 248,303.2 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ដៃគូអភិវឌ្ឍ | 521,632.7 | 477,765.8 | 291,545.5 | 1,290,944.0 | | | | |
| | 387,505.7 | 435,394.1 | 583,416.2 | 1,406,316.0 | សរុប | 149,858.6 | 142,509.8 | 143,246.1 | 435,614.5 | 237,647.1 | 292,884.3 | 440,170.1 | 970,701.5 |
| គម្រោងសម្រាប់អនុវត្តជ.យ.អ.ជ. | | | | | រាជរដ្ឋាភិបាល | 23,553.4 | 5,911.2 | 5,399.9 | 34,864.5 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 126,305.2 | 136,598.6 | 137,846.2 | 400,750.0 | | | | |
| | 1,002,077.3 | 1,020,058.5 | 971,600.5 | 2,993,736.3 | សរុប | 756,849.5 | 702,343.2 | 515,669.0 | 1,974,861.7 | 245,227.8 | 317,715.3 | 455,931.5 | 1,018,874.6 |
| សរុប | | | | | រាជរដ្ឋាភិបាល | 108,911.6 | 87,978.8 | 86,277.3 | 283,167.7 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 647,937.9 | 614,364.4 | 429,391.7 | 1,691,694.0 | | | | |
| ១.អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីននិងសង្គ្រោះជនពិការដោយសារមីន | | | | | | | | | | | | | |
| | 34,920.3 | 34,945.0 | 34,973.6 | 104,838.9 | សរុប | 31,243.4 | 31,243.4 | 31,243.4 | 93,730.2 | 3,676.9 | 3,701.6 | 3,730.2 | 11,108.7 |
| គម្រោងកំពុងដំណើរការ | | | | | រាជរដ្ឋាភិបាល | 5,111.4 | 5,111.4 | 5,111.4 | 15,334.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 26,132.0 | 26,132.0 | 26,132.0 | 78,396.0 | | | | |
| | 0.0 | 0.0 | 0.0 | 0.0 | សរុប | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| គម្រោងសម្រាប់អនុវត្តជ.យ.អ.ជ. | | | | | រាជរដ្ឋាភិបាល | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 0.0 | 0.0 | 0.0 | 0.0 | | | | |
| | 34,920.3 | 34,945.0 | 34,973.6 | 104,838.9 | សរុប | 31,243.4 | 31,243.4 | 31,243.4 | 93,730.2 | 3,676.9 | 3,701.6 | 3,730.2 | 11,108.7 |
| សរុប | | | | | រាជរដ្ឋាភិបាល | 5,111.4 | 5,111.4 | 5,111.4 | 15,334.2 | | | | |
| | | | | | ដៃគូអភិវឌ្ឍ | 26,132.0 | 26,132.0 | 26,132.0 | 78,396.0 | | | | |
| ២.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | | | | | | | | | | | |
| | 11,388.2 | 9,687.4 | 7,288.5 | 28,364.1 | សរុប | 11,388.2 | 9,687.4 | 7,288.5 | 28,364.1 | 0.0 | 0.0 | 0.0 | 0.0 |
| គម្រោងកំពុងដំណើរការ | | | | | រាជរដ្ឋាភិបាល | 1,663.0 | 1,792.0 | 1,530.0 | 4,985.0 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ដៃគូអភិវឌ្ឍ | 9,725.2 | 7,895.4 | 5,758.5 | 23,379.1 | | | | |
